

កាលពីព្រេងនាយ មានលោកតាម្នាក់បានដាំឆៃថាវ។
គាត់ក៏បាននិយាយ « កូនឆៃថាវអើយកូនឆៃថាវ ឯងត្រូវតែឆាប់ធំឡើង
មានមើមធំនិងមានរសជាតិឆ្ងាញ់ »។



កូនដំណាំថាវបានលូតលាស់ស្លឹកខៀវស្រងាត់ មើលទៅមានរសជាតិឆ្ងាញ់
ហើយមើមវាពិតជាធំខ្លាំងណាស់។



នៅថ្ងៃមួយ លោកតាក៏បានទៅដកមើមឆៃថាវនោះ។
លោកតាបានខំប្រឹងទាញមើមឆៃថាវនោះម្ដងហើយម្ដងទៀត នៅតែទាញមិនរួច។



លោកតាក៏បានទៅហៅលោកយាយឱ្យមកជួយ។
លោកយាយទាញលោកតា លោកតាទាញមើមឆៃថាវ។
ពួកគេបានខំប្រឹងទាញមើមឆៃថាវនោះម្ដងហើយម្ដងទៀត ប៉ុន្តែនៅតែទាញមិនរួច។



ដូច្នេះលោកយាយក៏បានទៅហៅចៅស្រីរបស់គាត់ឱ្យមកជួយ។
ចៅស្រីទាញលោកយាយ លោកយាយទាញលោកតា ហើយលោកតាទាញមើមឆៃថាវ។
ពួកគេបានទាញមើមឆៃថាវនោះម្តងហើយម្តងទៀត នៅតែមិនរួច។



ចៅស្រីបានទៅហៅកូនក្របីឱ្យមកជួយ។ កូនក្របីទាញចៅស្រី ចៅស្រីទាញលោកយាយ
លោកយាយទាញលោកតា លោកតាទាញមើមឆៃ៉ថាវ។
ពួកគេបានទាញមើមឆៃ៉ថាវនោះម្ដងហើយម្ដងទៀត ប៉ុន្តែនៅតែមិនរួច។



កូនក្របីក៏បានទៅហៅកូនស្វាឱ្យមកជួយ។ កូនស្វាទាញកូនក្របី កូនក្របីទាញចៅស្រី ចៅស្រីទាញលោកយាយ លោកយាយទាញលោកតា លោកតាទាញមើមឆៃថាវ។ ពួកគេបានខំប្រឹងទាញឆៃថាវនោះម្ដងហើយម្ដងទៀត ប៉ុន្តែនៅតែមិនរួច។



កូនស្វាបានទៅហៅអណ្ដើកឱ្យមកជួយ។ អណ្ដើកទាញកូនស្វា កូនស្វាទាញកូនក្របី កូនក្របីទាញចៅស្រី ចៅស្រីទាញលោកយាយ លោកយាយទាញលោកតា លោកតាទាញមើមឆៃថាវ។

ពួកគេបានខំប្រឹងទាញមើមឆៃថាវនោះម្ដងហើយម្ដងទៀត...



...ចុងក្រោយ ពួកគេពិតជាធ្វើបានសម្រេចមែន។ ពួកគេដកមើមឆៃថាវនោះបានហើយ!




# មើមឆៃថាវដ៏ធំ

និពន្ធ និងរូបភាពដោយ សិស្សនៅ ប្រទេសជប៉ុន

គំនូរជីវចល

ធនធានបង្រៀន

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

TUKTUK

Rotary